# ព្រះរាជក្រម

នស/រកម/០៥១៥/០០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា ២៣
# នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

**មាត្រាតែមួយ.-**

មាត្រា ២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោមៈ

**មាត្រា ២៣ ថ្មី.-**

រូបមន្តសម្រាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រម្នាក់ៗ ត្រូវផ្អែកលើប្រាក់បំណាច់តំណាងរាស្ត្រ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង ក្នុងរយៈពេលមួយឆ្នាំ នៃឆ្នាំណាមួយដែលមានចំនួនទឹកប្រាក់អតិបរមា ដោយកំណត់ស្មើនឹង ១០០% (មួយរយភាគរយ) ។

ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅៈ

-ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបាន សន្ទស្សន៍ ០,៥%

-លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ១%

-ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ ២%

-ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣%

-ពី ១៦ ឆ្នាំ ឡើងទៅទទួលបានសន្ទស្សន៍ ៤%

-ចំពោះតំណាងរាស្ត្រក្នុងតំណែងបីអាណត្តិបន្តបន្ទាប់គ្នាទទួលបានសន្ទស្សន៍ ៤%

អតីតតំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព វៀរលែងតែត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម/០៥១៥/០០៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៤៦៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**